

# វិធីដោះស្រាយ
# “ទំនាស់ឬខខាទ”

រៀបរៀងដោយៈ
លោក សំ សត្យា
អនុប្រធាននាយកដ្ឋាន
កិច្ចការរដ្ឋបាលនិង
នីតិកម្ម
នៃរដ្ឋបាលជលផល







សណ្ឋាគារតនលីណា ថ្ងៃទី១០-១១ ខែឧសភា ឆ្នាំ២០១២



# ផ្នែកទី ១

## ស្វែងយល់អំពី:

១. និយមន័យ“ទំនាស់ឬវិវាទ”

២. មូលហេតុ“ទំនាស់ឬវិវាទ”













# ១. និយមន័យ“ទំនាស់ឬវិវាទ”

### សម្តេចសង្ឃរាជ ជួន ណាត

ពាក្យ"**ទំនាស់**" កំណត់ថា:
ដំណើរ សេចក្តី អំពើដែលទាស់ ដែលផ្ទុយគ្នា
ដែលទីទៃពីគ្នាទៅជាទំនាស់។

ពាក្យ"**វិវាទ**" កំណត់ថា:
ជាដំណើរទាស់ទែងគ្នា ដំណើរឈ្លោះប្រកែកគ្នា
មានវិវាទកើតវិវាទនឹងគ្នា។

សង្ខេបមកពាក្យ "**ទំនាស់ឬវិវាទ**" គឺជា
ដំណើរដែលផ្ទុយគ្នា ទាស់ទែងគ្នាឬឈ្លោះគ្នា
ហើយបង្កឱ្យមានទំនាស់ឬវិវាទឡើង។








# ១. និយមន័យ“ទំនាស់ឬវិវាទ”(ត)

## សៀវភៅឯកសារជំនួយស្មារតី

" ការសម្របសម្រួលដោះស្រាយទំនាស់ក្នុងសហគមន៍នេសាទ "

- **ទំនាស់** គឺជាភាពខុសគ្នារវាងជំនឿ គំនិត ឬការចាប់អារម្មណ៍រវាងមនុស្សពីរនាក់ឬច្រើនជាងដែលធ្វើឱ្យកើតមានបញ្ហា។
- **ទំនាស់** ជាដំណើរការនៃការចាប់ផ្តើមក្នុងពេលដែលភាគីម្ខាងយល់ឃើញថា ភាគីម្ខាងទៀតធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានមកលើខ្លួន។
- **ទំនាស់** ជាភាពចម្រូងចម្រាស់មួយក្នុងចំណោមភាគីពីរ ឬច្រើនដែលបង្កឡើងដោយការមិនយោគយល់គ្នា(អាត្មានិយម) ដើម្បីសម្រេចឱ្យបានគោលបំណងឬទទួលបាននូវផលប្រយោជន៍រៀងៗខ្លួន។







# ២. មូលហេតុ“ទំនាស់ឬវិវាទ”

**មានមូលហេតុច្រើនក្នុងនោះមូលហេតុសំខាន់ៗ រួមមាន ៖**

-ភាពក្រីក្រនិងតម្រូវការ
-ចំណេះដឹងនិងអំណាច
-ការប្រកួតប្រជែងនិងសេដ្ឋកិច្ច
-មនោគមវិជ្ជា ជំនឿ សាសនានិងទំនៀមទំលាប់-
-ការប្រើប្រាស់ធនធានធម្មជាតិ



# ២. មូលហេតុ“ទំនាស់ឬវិវាទ”(ត)



*ភាពក្រីក្រ:*

*គឺជាដើមហេតុមួយដែលបង្កឱ្យមនុស្សមាន ទំនាស់ឬវិវាទ ជាមួយគ្នា ជាពិសេសរវាងអ្នកក្រនិងអ្នកក្រ ។*



*តម្រូវការ:*

*បានធ្វើឱ្យមនុស្សមានទំនាស់ឬវិវាទជាមួយគ្នាឥត ឈប់ឈរ ព្រោះមហិច្ឆតារបស់មនុស្សពុំអាចកំណត់បាន។*

# ២. មូលហេតុ“ទំនាស់ឬវិវាទ”(ត)








**ចំណេះដឹង:**

ជាប្រភពនៃទំនាស់ឬវិវាទ ព្រោះអ្នកមានចំណេះដឹងទាប តែងតែទទួលរងនូវឥទ្ធិពលពីអ្នកមានចំណេះដឹងខ្ពស់ជាង ហើយទីបំផុតអ្នកមានចំណេះដឹងក្លាយជាជនរងគ្រោះ។

**អំណាច:**

អំណាចដែលសម្រេចដោយអត្តនោម័តនិងពុំបានគិតគូគ្រប់ជ្រុងជ្រោយប្រកបដោយសម្បជញ្ញៈ ជាមូលហេតុបង្កឱ្យមានទំនាស់ឬវិវាទកើតឡើង។



# ២. មូលហេតុ“ទំនាស់ឬវិវាទ”(ត)



**ការប្រកួតប្រជែង:**

ការប្រកួតប្រជែងបានបង្កឱ្យមានទំនាស់ឬវិវាទកើតឡើង ពីព្រោះគោលបំណងនៃការប្រកួតប្រជែងគឺ ដើម្បីឈ្នះ-ចាញ់ ដូច្នេះ គេត្រូវប្រើកលល្បិចតាមគ្រប់មធ្យោបាយ។



**សេដ្ឋកិច្ច:**

សេដ្ឋកិច្ចដែលពុំមានតុល្យភាព បានបង្កឱ្យមានទំនាស់ ឬវិវាទកើតឡើង ពីព្រោះអ្នកមានសេដ្ឋកិច្ចខ្ពស់តែងតែ កេងប្រវញ្ចអ្នកដែលរណបខ្លួន ជាពិសេសអ្នកដែលមាន សេដ្ឋកិច្ចទាបជាងជានិច្ច។



# ២. មូលហេតុ“ទំនាស់ឬវិវាទ”(ត)



**មនោគមវិជ្ជា ជំនឿ ឬសាសនា:**

ជានិច្ចកាលតែងមានទំនាស់ឬវិវាទកើតឡើង ពីព្រោះម្នាក់ៗតែងប្រកាន់ថា របស់ខ្លួនល្អត្រឹមត្រូវនិងល្អជាងរបស់អ្នកដទៃទៀតជានិច្ច។



**ទំនៀមទំលាប់:**

អ្វីដែលមនុស្សជឿជាក់ មនុស្សនឹងប្រតិបត្តិតាម។ ប៉ុន្តែករណីមានមនុស្សផ្សេងទៀតមកកែប្រែទំនៀមទំលាប់របស់ខ្លួននោះ ទីបំផុតទំនាស់ឬវិវាទត្រូវតែកើតឡើង ។ រហូតដល់មានពាក្យបុរាណខ្មែរមួយពោលថា ទំលាប់ធំជាងច្បាប់។

# ២. មូលហេតុ“ទំនាស់ឬវិវាទ”(ត)







**ធនធានធម្មជាតិ:**

ជាធនធានដែលកើតឡើងដោយឯកឯងនិងជាកម្មសិទ្ធិរួមរបស់មនុស្សជាតិ។ ហេតុនេះហើយ ការប្រើប្រាស់ធនធានធម្មជាតិតែងតែមានការប្រណាំងប្រជែងគ្នាដណ្តើមផលប្រយោជន៍គ្នានទីបំផុតទៅតាមមហិច្ឆតារបស់ខ្លួនរៀងៗខ្លួន។ ចុងក្រោយបញ្ហា"ទំនាស់ឬវិវាទ"ត្រូវបានកើតឡើង។



# វេទិកាចូលរួមចែករំលែក
# បទពិសោធន៍វិធីដោះស្រាយ”ទំនាស់ឬវិវាទ”របស់បណ្តាខណ្ឌរដ្ឋបាលជលផល

**តើមាន ”ទំនាស់ឬវិវាទ” អ្វីខ្លះនៅក្នុងអង្គភាពរបស់អ្នក?**

**តើកន្លងមក អ្នកដោះស្រាយបញ្ហា“ទំនាស់ឬវិវាទ”ទាំងនោះតាមវិធីណា? ហើយមានប្រសិទ្ធភាពយ៉ាងណាដែរ ?**



រៀបចំបទបង្ហាញរយៈពេល ១៥ នាទី

ការធ្វើបទបង្ហាញរយៈពេល ៨ នាទី





តើត្រីនេះជារបស់អ្នកណា?





# ផ្នែកទី ២

## វិធីដោះស្រាយក្រៅប្រព័ន្ធតុលាការ

១ -ការចរចា

២ -ការផ្សះផ្សា

៣ -សន្ធានកម្មឬការសម្រុះសម្រួល





# វិធីដោះស្រាយក្រៅប្រព័ន្ធតុលាការ

១-ការចរចា:

ជាវិធីដោះស្រាយ "ទំនាស់ឬវិវាទ" ដោយគូភាគីជម្លោះដែលបង្ហាញឆន្ទៈរៀងខ្លួន ដើម្បីបញ្ចប់បញ្ហាគ្មានជនទី៣ ចូលរួមនិងជាវិធីមួយសមញ្ញបំផុតក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ការចរចាក៏អាចមានតំណាងមកបញ្ចុះបញ្ចូលគូភាគីបានដែរ ដើម្បីឱ្យត្រូវរូវគ្នា។

វិធីដោះស្រាយនេះប្រើបានតែរឿងរដ្ឋប្បវេណីប៉ុណ្ណោះ ប៉ុន្តែគេពុំអាចប្រើវិធីនេះ សម្រាប់ដោះស្រាយ "ទំនាស់ឬវិវាទ" នៅក្នុងរឿងព្រហ្មទណ្ឌបានទេ។

ជាគោលការណ៍នាពេលដោះស្រាយ "ទំនាស់ឬវិវាទ" ចប់ តម្រូវឱ្យមានកំណត់ហេតុនិងចុះហត្ថលេខាដោយគូភាគីជម្លោះ។

# វិធីដោះស្រាយក្រៅប្រព័ន្ធតុលាការ(ត)



## ១-ការចរចា:(ត)

### ១-១-គោលការណ៍នៃការចរចា:

-ភាគីម្ខាងនៃជម្លោះព្យាយាមសស្តាប់ការអធិប្បាយភាគីម្ខាងទៀត ដើម្បីទទួលបានព័ត៌មានសំខាន់ៗនិងធ្វើការវាយតម្លៃ។

-ព្យាយាមទប់អារម្មណ៍ឱ្យស្ងប់រកដំណោះស្រាយដោយសន្តិវិធីតាមរយៈការជជែកគ្នា ដើម្បីរកមូលហេតុ។

-ស្វែកយល់ផលប្រយោជន៍របស់ភាគីនីមួយៗ ហើយបន្ទាប់មក ត្រូវប្រើវិធីបំពេញផលប្រយោជន៍នោះបើអាចធ្វើទៅបាន។ ក្នុងករណីចរចាឯកភាពគ្នា ត្រូវសរសេរចុះក្នុងកិច្ចសន្យាថ្មី។





# វិធីដោះស្រាយក្រៅប្រព័ន្ធតុលាការ(ត)

## ១-ការចរចា:(ត)

### ១-២-យុទ្ធវិធីនៃការចរចា:

ការចរចាទទួលបានលទ្ធផល លុះត្រាគូភាគីជឿជាក់ថា បន្ទាប់ពីចរចារួច ពួកគេនឹងទទួលបានលទ្ធផលពីការចរចានោះ។

-ការចរចាដោយឈ្នះ-ឈ្នះ។ មានន័យថា ការចរចាបានផ្ដល់ផលប្រយោជន៍ដល់គូភាគី។

-ការចរចាដោយឈ្នះ-ចាញ់។ មានន័យថា ការចរចានេះមានផលប្រយោជន៍តែភាគីម្ខាង។





# យុទ្ធវិធី ឈ្នះ-ឈ្នះ



មុនចរចា

ការចរចា

យុទ្ធវិធី
ឈ្នះ-ឈ្នះ





# វិធីដោះស្រាយក្រៅប្រព័ន្ធតុលាការ(ត)

## ២-ការផ្សះផ្សា

-ការដោះស្រាយ"ទំនាស់ឬវិវាទ" មានជនទី៣ ចូលអន្តរាគន៍ ហៅថា អ្នកផ្សះផ្សា ដើម្បីសម្របសម្រួលនិងស្វែងរកចំណុចរួមរបស់គូភាគីឈានទៅបញ្ចប់បញ្ហា។

-អ្នកផ្សះផ្សាអាចជាចៅក្រម ប៉ុន្តែលុះត្រាបណ្ដឹងរបស់ភាគីបានដាក់ចូលតុលាការរួចដោយមិនទាន់ចាត់ការជាផ្លូវការ។

-ករណីអ្នកផ្សះផ្សាមិនមែនចៅក្រម អ្នកផ្សះផ្សានោះត្រូវបានជ្រើសរើសឡើងដោយគូភាគីជម្លោះជាអាទិ៍ មេភូមិ មេឃុំ ព្រឹទ្ធាចារ្យ មនុស្សចាស់ ព្រះសង្ឃឬមនុស្សដែលគេគ្រប់គ្នាគោរពរាប់អាន ។

-ការផ្សះផ្សាគេច្រើនប្រើវិធីនេះដោះស្រាយក្នុងជម្លោះរដ្ឋប្បវេណី រដ្ឋបាលនិងជម្លោះរវាងរដ្ឋនិងរដ្ឋ។



# វិធីដោះស្រាយក្រៅប្រព័ន្ធតុលាការ(ត)





***៣-សន្ធានកម្មឬការសម្រុះសម្រួលៈ***

*-ជាវិធីដោះស្រាយ“ទំនាស់ឬវិវាទ”ស្រដៀងការផ្សះផ្សាដែរ។ ប៉ុន្តែខុសគ្នាត្រង់សន្ធានការីសកម្មជាងដោយខិតខំរកមូលហេតុនិងជាតុសំខាន់ៗលើកជាសំណើឱ្យភាគីទទួលយក។*

*-សន្ធានការី ត្រូវអព្យាក្រឹតនិងគ្មានភាពលំអៀង ហើយជ្រើសរើសដោយគូភាគី។ សន្ធានការីត្រូវស្តាប់ការរៀបរាប់របស់គូភាគីដើម្បីកំណត់បញ្ហាជម្លោះ។ បន្ទាប់មក ត្រូវសម្របសម្រួលឱ្យគូភាគីបានប្រាស្រ័យទាក់ទងជាមួយគ្នា ដើម្បីឈានទៅទៅចុះកិច្ចសន្យាថ្មីមួយដែលពួកគេបានព្រមព្រៀងគ្នា។ ករណីភាគីណាមួយមិនគោរពកិច្ចសន្យាថ្មីនេះ ភាគីម្ខាងទៀតមានសិទ្ធិប្តឹងទៅតុលាការបាន។*

*-សន្ធានកម្ម គេច្រើនធ្វើការដោះស្រាយក្នុងរឿងរដ្ឋបាល។*

# វិធីដោះស្រាយក្រៅប្រព័ន្ធតុលាការ(ត)





## ៣-១-ប្រភេទនៃសន្ទានកម្ម:

-ការសម្រុះសម្រួលដោយតុលាការ

មានន័យថា ពេលបណ្តឹងដាក់ចូលតុលាការ តុលាការចាត់ចៅ ក្រម១ រូបមកសម្រុះសម្រួល ដែលកិច្ចការនេះតុលាការមានលទ្ធភាពជាងការផ្សះផ្សា ។ ឯសេចក្តីសម្រេចរបស់ចៅក្រមខាងលើ គឺមានប្រសិទ្ធភាពក្នុងការដាក់ឱ្យអនុវត្ត។

-ការសម្រុះសម្រួលដោយឯកជន

ការសម្រុះសម្រួលនេះ ទទួលបានកិច្ចសន្យាថ្មីមួយ។ ក្នុងករណីមានភាគីណាមួយមិនគោរពកិច្ចសន្យាថ្មីនេះ នាំឱ្យភាគីម្ខាងទៀតមានសិទ្ធិដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីបង្ខំភាគីនោះអនុវត្ត។



# វិធីដោះស្រាយក្រៅប្រព័ន្ធតុលាការ(ត)



## ៣-២-កត្តាជោគជ័យសន្ទានកម្ម:

-គូភាគីត្រូវតែយល់ព្រមដោះស្រាយជម្លោះនេះ។ សន្ទានកម្មច្រើនអនុវត្តនៅពេលការចរចាបរាជ័យ។ គូភាគីត្រូវយល់ព្រមនិយាយអ្វីដែលបានជជែកគ្នារួច។

-សន្ទានការី ត្រូវតែមនុស្សអព្យាក្រឹត ទុកចិត្តនិងគួរឱ្យគោរព។ សន្ទានការីមាន មេធាវី មន្ត្រីរដ្ឋាភិបាល អ្នកដឹកនាំមូលដ្ឋាន អ្នកដឹកនាំសាសនា ឬពាណិជ្ជករដែលមានជំនាញ និងបទពិសោធន៍ក្នុងសង្គម។

-សន្ទានការីមុនដំបូងត្រូវជួបជាមួយភាគីម្នាក់ម្តងៗ រួចពន្យល់អំពីដំណើរការសម្រុះសម្រួលនិងសួរជុំវិញបញ្ហា អង្គហេតុនិអារម្មណ៍របស់ភាគីនីមួយៗតាមជំហានដូចតទៅ៖



# វិធីដោះស្រាយក្រៅប្រព័ន្ធតុលាការ(ត)



## ៣-២-កត្តាជោគជ័យរបស់សន្ទានកម្ម:(ត)

-ជំហ៊ានទី១ :

សន្ទានការី ត្រូវពន្យល់អំពីផលប្រយោជន៍និងបញ្ហារបស់គូភាគីដោយប្រើបច្ចេកទេសនិយាយដែលធ្វើឱ្យគូភាគីស្តាប់ក្តីងគោលបំណងបន្ទំអារម្មណ៍និងធ្វើយ៉ាងណាឱ្យគូបដិបក្សអាចប្រាស្រ័យទាក់ទងគ្នាបាន។

-ជំហ៊ានទី២ :

សន្ទានការី ត្រូវសង្ខេបបញ្ហានិងរៀបចំរបៀបវារៈដាក់ចូលក្នុងកិច្ចពិភាក្សារបស់គូភាគី។ ត្រូវបំបែករាល់បញ្ហានៅក្នុងកិច្ចពិភាក្សាំឱ្យបានច្បាស់លាស់និងពេញលេញ។ ត្រូវលើកទឹកចិត្តគូភាគីជម្លោះឱ្យយល់ចិត្តគ្នាទៅវិញទៅមក។





# វិធីដោះស្រាយក្រៅប្រព័ន្ធតុលាការ(ត)

## ៣-២-កត្តាជោគជ័យរបស់សន្ទានកម្ម:(ត)

-ជំហានទី៣ :

សន្ទានការី ត្រូវរកឱ្យឃើញលទ្ធផលនៃកិច្ចពិភាក្សា។ បន្ទាប់មក ត្រូវធ្វើការណែនាំគូភាគីទំនាស់ឱ្យធ្វើការរួមគ្នានិងរកជម្រើសដែលមានផលប្រយោជន៍ ហើយធ្វើការបែងចែកផលប្រយោជន៍ទៅវិញទៅមក។

-ជំហានទី៤ :



សន្ទានការី ត្រូវសរសេរកិច្ចសន្យាថ្មីទៅតាមលក្ខខណ្ឌផ្សេងៗដែលគូភាគីបានព្រមព្រៀងគ្នារួច។ ការសរសេរត្រូវច្បាស់លាស់ ពេញលេញនិងពន្យល់ខ្លឹមសារ។

សន្ទានការី ត្រូវតាមដានថា កិច្ចសន្យាថ្មីនេះ គូភាគីអាចអនុវត្តបានឬទេ ? រីឯគូភាគីវិញ ក៏អាចស្នើសុំសន្ទានការីឱ្យតាមដានភាគីណាមួយដែលមិនគោរពកិច្ចសន្យាថ្មីនោះបានដែរ។



# ផ្នែកទី ៣



## វិធីដោះស្រាយតាមប្រព័ន្ធតុលាការ

ជាវិធីដោះស្រាយផ្លូវការដោយស្ថាប័នតុលាការរដ្ឋ និងឯករាជ្យ។ ឯការវិនិច្ឆ័យតុលាការបានកំណត់អំពើប្រព្រឹត្ត ជាមួយច្បាប់។



អនុវត្តតាមនីតិវិធីនិងបើកសិទ្ធិឱ្យគូភាគីប្តឹងបន្តបាន។ សេចក្តីសម្រេចរបស់តុលាការមានអំណាច២ គឺ៖

អំណាចសម្រេចសេចក្តីនិងអំណាចបង្គាប់បញ្ជា។

ចំណែកវិធីដោះស្រាយវិញ មានអង្គភាព២ ទទួលបន្ទុកគឺ៖

-តុលាការឬសាលាជម្រះក្តីសាធារណៈ

-មជ្ឈត្តការឬតុលាការអាជ្ញាកណ្តាល

# វិធីដោះស្រាយតាមប្រព័ន្ធតុលាការ(ត)



១-តុលាការឬសាលាជម្រះក្តីសាធារណៈ

ជាសេវាសាធារណៈផ្នែកយុត្តិធម៌របស់រដ្ឋៗទទួលជម្រះ គ្រប់រឿងក្តី(រដ្ឋបាលនិងឯកជន) ឱ្យតែទទួលបានពាក្យបណ្តឹងៗ ទោះបីមានច្បាប់ចែងឬគ្មានក្តីៗ តុលាការក៏អាចសម្រេចសេចក្តី តាមសមធម៌បានដែរៗ ចំណែក អ្នកមានអំណាចសម្រេច សេចក្តីគឺ<u>ចៅក្រម</u>ៗ



# វិធីដោះស្រាយតាមប្រព័ន្ធតុលាការ(ត)



១-តុលាការឬសាលាជម្រះក្តីសាធារណៈ(ត)




គោលការណ៍ទូទៅ:

-គោលការណ៍និរន្តរភាព

-គោលការណ៍សមភាព

ចំពោះគោលការណ៍នេះ មានការលើកលែងករណីការលើកលែងដោយច្បាប់និងស្ថានភាពសេដ្ឋកិច្ចនិងសង្គម។

-គោលការណ៍មិនយកកម្រៃសេវាសាធារណៈ

-គោលការណ៍រៀបចំប្រព័ន្ធតុលាការ២ ថ្នាក់

-គោលការណ៍អព្យាក្រឹត

គោលការណ៍អព្យាក្រឹត មានន័យថា តុលាការជានាផ្នែកបច្ចេកទេស(អនុវត្តនីតិវិធីនិងច្បាប់)និងជានាផ្នែកសង្គម(មិនលំអៀង បក្សពួក ឋានៈសង្គម)។



# វិធីដោះស្រាយតាមប្រព័ន្ធតុលាការ(ត)

១-តុលាការឬសាលាជម្រះក្តីសាធារណៈ(ត)

ការរៀបចំប្រព័ន្ធតុលាការកម្ពុជាមាន២ ថ្នាក់គឺ៖

ក-តុលាការជាន់ទាប

-សាលាដំបូងរាជធានី ខេត្ត(គ្រប់ខេត្តនិងរាជធានី)

-តុលាការយោធា(មាន១ ស្ថិតនៅរាជធានីភ្នំពេញ)

ខ-តុលាការជាន់ខ្ពស់

-សាលាឧទ្ធរណ៍(មាន១ ស្ថិតនៅរាជធានីភ្នំពេញ)

-តុលាការកំពូល(មាន១ ស្ថិតនៅរាជធានីភ្នំពេញ)



# វិធីដោះស្រាយតាមប្រព័ន្ធតុលាការ(ត)



១-តុលាការឬសាលាជម្រះក្តីសាធារណៈ(ត)

ក-សមាសភាពមន្ត្រីរាជការនៅតុលាការជាន់ទាបៈ

-ផ្នែកចៅក្រម

-ផ្នែកអយ្យការ

-ក្រឡាបញ្ជីនិងមន្ត្រីរដ្ឋបាល

ខ-សមាសភាពមន្ត្រីរាជការនៅតុលាការជាន់ខ្ពស់ៈ

-ផ្នែកចៅក្រម

-ផ្នែកមហាអយ្យការ(ករណីសាលាឧទ្ធរណ៍មាន នាយកដ្ឋានព្រហ្មទណ្ឌនិងនាយកដ្ឋានរដ្ឋប្បវេណី) ។ ចំណែក តុលាការកំពូលមានមន្ទីររដ្ឋបាលរួម១ ក្នុងនោះមាន៤ ការិយាល័យក្រោមចំណុះ។



# វិធីដោះស្រាយតាមប្រព័ន្ធតុលាការ(ត)

២-មជ្ឈត្តការឬតុលាការអាជ្ញាកណ្តាល ឬមជ្ឈត្តវិនិច្ឆ័យ ជាសាលាជម្រះក្តីឯកជនប៉ុន្តែមានមុខងារដូចសាលាជម្រះក្តីរដ្ឋដែរ។ សាលាជម្រះក្តីនេះ មានផលប្រយោជន៍ឆាប់រហ័សនិងចំណាយថវិកាតិច។ មានសមត្ថកិច្ចដោះស្រាយវិវាទការងារនិងពាណិជ្ជកម្មនិងវិវាទរវាងរដ្ឋនឹងរដ្ឋ។ ប៉ុន្តែហាមឃាត់ដោះស្រាយវិវាទរដ្ឋបាល។

តុលាការអាជ្ញាកណ្តាលមានសមត្ថកិច្ច លុះត្រា ៖

-មានការព្រមព្រៀងអំពីគូភាគីជម្លោះ

-ឯកភាពគ្នាទទួលយកមជ្ឈត្តករ

-សម្រេចសេចក្តីតាមច្បាប់ ប៉ុន្តែអាចសម្រេចតាមសមធម៌បាន។





# វិធីដោះស្រាយតាមប្រព័ន្ធតុលាការ(ត)

ក-មជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា

មជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជាបង្កើតឡើងនៅឆ្នាំ ២០០៩ តាមរយៈអនុក្រឹត្យលេខ១២៤ អនក្រ. បក ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០០៩។

ខ-គណៈកម្មការដោះស្រាយវិវាទការងារនៅកម្ពុជា

វិវាទការងារ ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១០ តាមរយៈប្រកាសលេខ១៧៧ កប/ប្រក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០១០ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

គ- មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិមួយចំនួន:







ត្រីនេះរបស់អញទេ!

សូមអរគុណ!

